**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ២៩៦៣ ព.ណ.ជ.ម.ព

# សេចក្តីជូនដំណឹង
## ស្តីពី ការបម្រុងទុកនាមករណ៍ក្រុមហ៊ុន-សហគ្រាស

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូន លោក លោកស្រី ដែលមានបំណងបម្រុងទុកនាមករណ៍ជ្រាបថាៈ បុគ្គលស្នើសុំ អាចធ្វើការចុះអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដោយបំពេញបែបបទស្នើសុំចុះបញ្ជីក្រុមហ៊ុន-សហគ្រាសរួមជាមួយនាមករណ៍ក្នុងពេលតែមួយ ឬអាចស្នើសុំបម្រុងទុកនាមករណ៍ជាមុនដើម្បីធ្វើការស្នើសុំចុះបញ្ជីអាជីវកម្ម តាមក្រោយ។

ក្នុងករណីបុគ្គលស្នើសុំ មានបំណងចង់បម្រុងទុកនាមករណ៍ជាមុន បុគ្គលស្នើសុំម្នាក់អាចបម្រុងទុកនាមករណ៍បានតែចំនួន ០៣(បី) នាមករណ៍ប៉ុណ្ណោះ ដែលនាមករណ៍នីមួយៗមានសុពលភាពត្រឹមតែ ០២(ពីរ) សប្តាហ៍។ ករណីដែលនាមករណ៍ណាមួយហួសសុពលភាព បុគ្គលស្នើសុំអាចធ្វើការស្នើសុំបម្រុងនាមករណ៍ដដែលនោះបន្តសាឡើងវិញយ៉ាងតិចបំផុតឱ្យបាន ០១(មួយ)ថ្ងៃ មុនកាលបរិច្ឆេទហួសសុពលភាព។ ការស្នើសុំបម្រុងនាមករណ៍បន្តនេះ អាចធ្វើបានតែម្តងប៉ុណ្ណោះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី ជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ តុលា ឆ្នាំ២០២០

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469